**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**

សំណុំរឿងព្រហ្មទណ្ឌ

លេខ: ១០៥

ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៤

# **នាមនាមប្រជារាស្ត្រខ្មែរ**

**តុលាការកំពូល**

**សាលដីកា**

លេខ: ៤៤

ចុះថ្ងៃទី២៤ខែឧសភាឆ្នាំ២០០៦

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៦ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចតទៅ:

១- ឯកឧត្តម **ឃឹម ប៉ុណ្ណ** ប្រធាន

២- លោក ឈឹម ស៊ីផល ចៅក្រម

៣- លោក រៀល មួន ចៅក្រម

៤- លោក ម៉ុង មុន្នីចរិយា ចៅក្រមរបាយការណ៍

៥- លោក ប៉ែន សារឿន ចៅក្រម

ក្រឡាបញ្ជី

លោក សាន សុជាត

**តំណាងមហាអយ្យការ**

លោក ស៊ិន រិទ្ធ ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ៧៣"គ" ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ ១០៥ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៤ របស់តុលាការកំពូល ។

<u>**ពិរុទ្ធ:**</u> បង្ករបួសស្នាមដោយចេតនា ប្រព្រឹត្តនៅភូមិស្តៅកោង ឃុំស្ដី(ក) ស្រុកបាភ្នំ ខេត្តព្រៃវែង កាលពីថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៩៩ ។

-ជនជាប់ចោទឈ្មោះ ខឹយ ហឿន (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទស្រី អាយុ២១ឆ្នាំ ជាតិខ្មែរ របររកស៊ី ធ្វើស្រែ ទីលំនៅសព្វថ្ងៃ ភូមិស្តៅកោង ឃុំស្ដី(ក) ស្រុកបាភ្នំ ខេត្តព្រៃវែង ។ ឪពុកឈ្មោះ ប៉ាង ខឹយ ម្តាយឈ្មោះ ខេង នាង (ស)ប្តីឈ្មោះទូច ទិត្យ មានកូន០២នាក់ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ឃ្លោក ពៅ (ជាចុងបណ្តឹងសាទុក្ខ)ភេទស្រី អាយុ៦៤ឆ្នាំ ជាតិខ្មែរ របររកស៊ី ធ្វើស្រែ ទីលំនៅសព្វថ្ងៃ ភូមិស្តៅកោង ឃុំស្ដី(ក) ស្រុកបាភ្នំ ខេត្តព្រៃវែង ។

-កាលពីខែមីនា ឆ្នាំ១៩៩៩ ម៉ោង.១១ថ្ងៃត្រង់ ខ្លួនទៅដេញមាន់ ស្រាប់តែមាន់របស់ ឈ្មោក ពៅ ចូលស៊ីស្រូវរបស់ខ្លួន ពេលនោះឈ្មោះ អ៊ុន អាត ចុះពីលើផ្ទះ ដោយគ្មានសួរខុសត្រូវក៏ជេរខ្លួន ម៉ីចោរទេចុយ ម៉ែងម៉េច ដេញមាន់អញ ! ពេលនោះខ្លួនខឹងពេកក៏យករំពាត់ឫស្សីប្រវែង ០២៣ វាយឈ្មោះ អ៊ុន អាត ត្រូវជើងចំនួន ០៣រំពាត់ ហើយអ៊ុត អាត ក៏យកកាំបិតមកដេញកាប់ខ្លួន ពេលនោះខ្លួនរត់ទៅផ្ទះ ។ប្រហែលកន្លះម៉ោងឈ្មោះ ឈ្មោក ពៅ ត្រូវជាយាយរបស់ អ៊ុន អាត បានមកផ្ទះខ្លួន ហើយស្រែកថា មី ហឿន ម៉ែងចុះមកមើល ខ្លួនក៏ចុះ ហើយគាត់ក៏យករំពាត់ដែលខ្លួនវាយចៅគាត់នោះ មកបុកខ្លួនតែម្តងតែពុំត្រូវ បែរជាត្រូវកូនខ្លួនដែលពរនៅដៃ យាយពៅ បោចសក់ខ្លួន វាយខ្លួនត្រូវកខាងឆ្វេង ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ អមតុលាការខេត្តព្រៃវែង ថា: ចោទប្រកាន់ ខឹយ ហឿន នៅភូមិស្តៅកោង ឃុំស៊ី្ត(ក) ស្រុកបាភ្នំ ខេត្តព្រៃវែង កាលពីថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៩៩ ដែលមានចែងឱ្យផ្តន្ទាទោស តាមមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ៦១ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៩ របស់តុលាការខេត្តព្រៃវែង ដែលបានសំរេច:

១-ផ្តន្ទាទោសលើឈ្មោះខឹយ ហឿន កំណត់ ២ខែ តែទោសនេះព្យួរទាំងស្រុង និងសាកល្បងរយ:ពេល៥ឆ្នាំ ចាប់គិតពីថ្ងៃនេះតទៅ ។

២-បង្គាប់អោយ ខឹយ ហឿន បង់ប្រាក់សងទៅឱ្យដល់ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៤០ម៉ឺន ថ្លៃថ្នាំព្យាបាល និងជំងឺចិត្ត សុំលើសពីនេះ បដិសេធចោល ។

ក្នុងករណីឈ្មោះ ខឹយ ហឿន គ្មានប្រាក់ធនទ័ណ្ឌគ្រប់ចំនួនសងទៅដើមបណ្តឹងរដ្ឋប្បវេណីទៅនោះ ត្រូវរឹបអូសទ្រព្យសម្បត្តិដែលមានលក់ឡាយឡុង ដើម្បីយកប្រាក់សង តែបើលក់ទ្រព្យសម្បត្តិហើយ សងនៅតែមិនគ្រប់ ត្រូវដាក់គុកបង្ខំលើរូបរាងកាយក្នុងរឿងព្រហ្មទណ្ឌដែលប្រកាសឱ្យប្រើតាមក្រិត្យលេខ១៨ ចុះថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ១៩៩២ ។

ពីបទ : បង្ករបួសស្នាមដោយចេតនា ប្រព្រឹត្តនៅភូមិស្តៅកោង ឃុំស៊ី្ត(ក) ស្រុកបាភ្នំ ខេត្តព្រៃវែង កាលពីថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៩៩ ។ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមមាត្រា៤១ .៦៨ និង៧០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៣-សាលក្រមនេះ ជំនុំជំរះ និងប្រកាសជាសាធារណៈ ចំពោះមុខគូក្តី បើគូក្តីណាមិនសុខចិត្ត និងសេចក្តីសំរេចនេះទេ បើកផ្លូវឱ្យប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ១១ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ១៩៩៩ របស់ឈ្មោះ ខឹយ ហឿន ដែលប្តឹងមិនសុខចិត្តពីសាលក្រមព្រហ្មទណ្ឌលេខ៦១ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៩ របស់តុលាការខេត្តព្រៃវែង លើសេចក្តីសំរេចទាំងមូល ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមសាលាឧទ្ធរណ៍ ថា:

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ១១ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ១៩៩៩ របស់ឈ្មោះខឹយ ហឿន ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោល ដោយទាស់ និងគតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ៦១ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៩ របស់តុលាការខេត្តព្រៃវែង ទុកជាបានការតទៅ ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ៦៥"ក" ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ដែលបានសំរេច:

១-ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៩៩ របស់ឈ្មោះខឹយ ហឿន ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយទាស់ នឹងគតិច្បាប់ ។

២-តំកល់សាលក្រមព្រហ្មទណ្ឌលេខ៦១ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៩ របស់តុលាការខេត្តព្រៃវែងទុកជាបានការដដែល ។

៣-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈ កំបាំងមុខជនជាប់ចោទ និង ដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

-បានឃើញបណ្តឹងសាទុក្ខលេខ២៨ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០០៣ របស់ឈ្មោះ ខឹយ ហឿន ប្តឹងមិនសុខចិត្តពីសាលដីកាព្រហ្មទណ្ឌលេខ៦៥"ក"ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

-បានឃើញពាក្យសុំដកបណ្តឹងសាទុក្ខ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០០៤ របស់ឈ្មោះខឹយ ហឿន ជាម្ចាស់បណ្តឹងសាទុក្ខ ។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមតុលាការកំពូលថា: គ្មានយោបល់ជំទាស់ទេ គប្បីអនុញ្ញាតិឱ្យជនជាប់ចោទ ដកបណ្តឹងសាទុក្ខតាមសុំ ។

-ក្រឡាបញ្ជីអានពាក្យសុំដកបណ្តឹងសាទុក្ខ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០០៤ របស់ឈ្មោះខឹយ ហឿន ជាម្ចាស់បណ្តឹងសាទុក្ខ ។

-ក្រោយពីបានស្តាប់ពាក្យសុំដកបណ្តឹងសាទុក្ខ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០០៤ របស់ម្ចាស់បណ្តឹងសាទុក្ខឈ្មោះខឹយ ហឿន ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ២៨ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០០៣ របស់ឈ្មោះខឹយ ហឿន ស្ថិតក្នុងកំណត់ច្បាប់តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបាន តាមមាត្រា១៤នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា តាមពាក្យសុំចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០០៤ អ្នកស្រី ខឹយ ហឿន ជាម្ចាស់បណ្ដឹងសាទុក្ខ បានសុំដកបណ្ដឹងសាទុក្ខរបស់ខ្លួនវិញហើយ ដោយមានការបញ្ជាក់ លោកមេឃុំស្អិ(ក)ផងដែរ ដែលតុលាការកំពូល អាចពិចារណា និងសំរេចបាន ។

-យល់ឃើញថា ម្ចាស់បណ្ដឹងសាទុក្ខបានសុំដកបណ្ដឹងរបស់ខ្លួនវិញហើយៗ ពុំបានមកចូលរួមសវនាការនេះទេ ដូច្នេះតុលាការកំពូលជំនុំជំរះរឿងនេះ កំបាំងមុខឈ្មោះនេះ ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

-យល់ឃើញថា ដើមបណ្ដឹងរដ្ឋប្បវេណីពុំបានប្ដឹងសាទុក្ខទេ ហើយតាមសំបុត្រមរណៈភាពលេខ២០ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៥ ដើមបណ្ដឹងរដ្ឋប្បវេណីបានទទួលមរណៈភាពហើយ ហើយពុំមានការចាត់តាំងអ្នកតំណាងទេ ដូច្នេះគប្បីប្រគល់ផលប្រយោជន៍ ត្រូវបានទៅអោយទាយាទរបស់មរតកជនរូបនេះ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្ដីកំបាំងមុខជាស្ថាពរ ប៉ុន្តែចាត់ទុកជាចំពោះមុខ**

១-ទទួលពាក្យសុំដកបណ្ដឹងសាទុក្ខចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០០៤ របស់អ្នកស្រី ខឹយ ហឿន ទុកជាត្រឹមត្រូវតាមច្បាប់ ។

២-អនុញ្ញាតិឱ្យអ្នកស្រី ខឹយ ហឿន ដកបណ្ដឹងសាទុក្ខរបស់ខ្លួនតាមសុំ ។

៣-បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ១០៥ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៤ របស់តុលាការកំពង់ឆ្នាំង ទៅសាលាឧទ្ធរណ៍ ដើម្បីចាត់ការតាមច្បាប់ ។

៤-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៦ ។